**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១១០៥ ព.ណ.គ.ន..

ថ្ងៃ សុក្រ ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈជនទាំងអស់មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងចាប់ផ្តើមអនុវត្តប្រកាសអន្តរក្រសួងលេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម និងប្រកាសអន្តរក្រសួងលេខ៣១៦ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ស្តីពីការពិន័យជាប្រាក់ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ចាប់ពី **ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១** តទៅ។ តារាងស្តីពីកម្រងសេវាសាធារណៈនៃប្រកាសអន្តរក្រសួងនេះ មានបិទផ្សាយនៅទីស្តីការក្រសួងពាណិជ្ជកម្ម តាមបណ្តានាយកដ្ឋានជំនាញ បញ្ជរបង់ប្រាក់រួមក្រសួងពាណិជ្ជកម្ម និងតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម www.moc.gov.kh ។

ក្រុមហ៊ុន សហគ្រាស និងអ្នកនាំចេញ ដែលបាននាំចេញទំនិញពីកម្ពុជា ហើយមិនតម្រូវការវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ គឺត្រូវបន្តអនុវត្តខ្លឹមសារប្រកាសអន្តរក្រសួងលេខ ១៦២៧សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទៅក្រៅប្រទេស ដើម្បីក្រសួងពាណិជ្ជកម្មមានមូលដ្ឋានស្រង់ស្ថិតិ និងធ្វើការកាត់សន្និធិវត្ថុធាតុដើមនាំចូលប្រចាំខែរបស់ក្រុមហ៊ុន សហគ្រាស ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម